# BLUEPRINT

# ផែនការអភិវឌ្ឍន៍វិស័យសេដ្ឋកិច្ច

## បង្កើតឱកាសសេដ្ឋកិច្ច សម្រាប់និយោជិក វិនិយោគិន និងសហគ្រិន

Lakewood Village
Wrigley
Downtown
City of Long Beach
Uptown
Carmelitos
El Dorado Park
Bluff Heights
Zaferia
Belmont Shore

CITY OF LONGBEACH

# សារពីអភិបាលក្រុង

ការអភិវឌ្ឍសេដ្ឋកិច្ចគឺជាមូលដ្ឋានគ្រឹះ នៃចក្ខុវិស័យអភិវឌ្ឍន៍របស់គ ណៈអភិបាល ក្រុងឡុងប៊ិច ។ ទីក្រុងនេះបាននិងកំពុងទទួលបាន កំណើនខ្ពស់ គួរឱ្យកត់ សម្គាល់  នៅក្នុងសហគមន៍ តាំងពីពេលដែលបានវិនិយោគ ក្នុងទឹកប្រាក់ រាប់រយលានដុល្លារ ក្នុងការស្តារទីក្រុង ឱ្យមានភាពរីកចម្រើន ឡើងវិញ និងក្នុងគម្រោងកសាងទីប្រជុំជន រហូតដល់មានអាជីវកម្មរាប់រយ នៅមូលដ្ឋាន ដែលចាប់ បើកដំណើរការ ជារៀងរាល់ឆ្នាំ រហូតដល់ប្រែ ក្លាយជាតំបន់ពាណិជ្ជកម្មរីកលូតលាស់បានល្អ នៅជុំវិញទីក្រុង។ គណៈអភិបាលក្រុង ក៏បាន ដាក់ឱ្យប្រើប្រាស់ជាផ្លូវការ នូវច្រកពាណិជ្ជកម្មថ្មីមួយ មានឈ្មោះថា “ប៊ីសផត (BizPort)” ដែល អាចផ្តល់ ធនធានសំខាន់ៗ ជាច្រើន ដើម្បីជួយសហគ្រិន ក្នុងការបង្កើត និងដំណើរការអាជីវ កម្មរបស់ពួកគេ ។

ទោះបីជាមានកម្រិតអភិវឌ្ឍន៍យ៉ាងខ្ពស់បែបនេះក្តី ក៏សាលាក្រុងនៅតែមានការងារ ដែលត្រូវបំពេញបន្ថែមទៀតជានិច្ច ។ នេះហើយជាមូលហេតុ ដែលគណៈកម្មការអភិវឌ្ឍន៍សេដ្ឋ កិច្ច ត្រូវបានដឹកនាំឱ្យធ្វើការសិក្សាស្រាវជ្រាវ និងធ្វើសេចក្តីរាយការណ៍ត្រលប់មកវិញ ដោយមាន ភ្ជាប់នូវ សំណូមពរនានា ស្តីពីមធ្យោបាយដឹកនាំសេដ្ឋកិច្ចរបស់ទីក្រុងដ៏អស្ចារ្យនេះ នាពេល អនាគត ។ គណៈអភិបាលក្រុង ពិតជាមានភាពរីករាយក្រៃលែង ក្នុងការបង្ហាញពីផែនការ អភិវឌ្ឍន៍វិស័យសេដ្ឋកិច្ច រយៈពេល 10 ឆ្នាំ ដែលគូស បង្ហាញ ពីជំហានសំខាន់ៗ ជាបន្តបន្ទាប់ ក្នុងការអភិវឌ្ឍទីក្រុងឱ្យក្លាយទៅជា សេដ្ឋកិច្ចនាំមុខមួយ របស់ប្រទេសជាតិយើង  ។

វិស័យផ្តោតជាសំខាន់ នីមួយៗ ដែលមានរៀបរាប់ជាលម្អិត ក្នុងរបាយការណ៍នេះ នឹងផ្តល់ នូវ ទស្សនៈ ថ្មីៗ ជាច្រើន ចំពោះរបៀប ដែលគណៈអភិបាលក្រុង អាចលើកកម្ពស់ការអភិវឌ្ឍវិស័ យសេដ្ឋកិច្ច ដើម្បីផ្តល់ ឱកាសជាច្រើន ដល់អាជីវកម្ម និងបុគ្គលម្នាក់ៗ ឱ្យសម្រេចបាន ការរីក ចម្រើនលូតលាស់ ។ គណៈអភិបាល ក្រុង ក៏មានសេចក្តីត្រេកអរយ៉ាងខ្លាំងជាពិសេស ក្នុងកា របង្កើតឱ្យមាន ដំណើរការអភិវឌ្ឍន៍ទីក្រុង ប្រកបដោយប្រសិទ្ធភាពបន្ថែមទៀត ដើម្បីជួយគាំទ្រដល់ម្ចាស់អាជីវកម្មទាំងអស់ ហើយបង្ករបរិយាកាសមួយ ដែលមិនត្រឹមតែ ស្វាគមន៍ប៉ុណ្ណោះទេ គឺ ថែមទាំងលើកទឹកចិត្តដល់ភាពជាគូនានា នាពេលអនាគត ផងដែរ ។ ម្យ៉ាងទៀត ដោយមាន ការណែនាំ ពីគណៈកម្មការអភិវឌ្ឍន៍សេដ្ឋកិច្ច គណៈអភិបាលក្រុង មានជំនឿយ៉ាងមុតមាំថា ទី ក្រុងនេះអាចធានាបាននូវ ការវិនិយោគបន្ថែមទៀត ការជំរុញពាណិជ្ជកម្មអន្តរជាតិ ឱ្យរីក ចម្រើន និងការកែលំអ គុណភាពជីវិតជារួម នៅក្នុងទីក្រុងឡុងប៊ិច ។

**Dr. Robert Garcia, Mayor of Long Beach**

# សារ ពីប្រធានគណៈកម្មការអភិវឌ្ឍន៍សេដ្ឋកិច្ច

ជំរុញដោយចក្ខុវិស័យពលរដ្ឋ ដោយមានការវិនិយោគ ពីវិស័យឯកជន និងសាធារណ ទី ក្រុងឡុងប៊ិច កំពុងទទួលបាន កំណើនសេដ្ឋកិច្ច ដ៏អស្ចារ្យ ជាថ្មីម្តងទៀត ។ នេះជាពេល ដែល យើងត្រូវធានាថាភាពជោគជ័យ ផ្នែកសេដ្ឋកិច្ចនេះ នឹងមាននិរន្តរភាព ហើយអាចបញ្ជ្រាបផល ពីកំណើននេះ បានទៅ គ្រប់តំបន់ទាំងអស់ នៅទូទាំងទីក្រុង ។ ដើម្បីជំរុញ និងពង្រីក ការងារ និងគំនិតអាជីវកម្មថ្មីៗ ទាំងនេះ ពួកយើងត្រូវបណ្តុះ ឱ្យមានវប្បធម៌ "ឱកាសសេដ្ឋកិច្ច" នៅទូ ទាំងទីក្រុង ។ វប្បធម៌សេដ្ឋកិច្ចគង់វង្សមួយដែលលើកកម្ពស់ឥរិយាបថ "អាចធ្វើបាន" និងកិច្ច សហការ ក្នុងចំណោមប្រជាពលរដ្ឋ នៅក្នុងទីក្រុង និងដៃគូរដ្ឋាភិបាល ទាំងអស់ ក្នុងការបង្កើត ឱ្យមាន "ទីក្រុង ប្រកបដោយឱកាស" មួយពិតប្រាកដសម្រាប់ទីក្រុងឡុងប៊ិច។

ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច ក្នុងរយៈពេល 10 ឆ្នាំ នេះ បង្ហាញពីយុទ្ធសាស្រ្ត ពង្រឹងក្បាលម៉ាស៊ីនសេដ្ឋកិច្ចរបស់ទីក្រុង បណ្តុះ និងជំរុញឧស្សាហកម្មកែច្នៃថ្មីៗ និងលើកកម្ពស់ឱ្យមាន បរិយាប័ន្នផ្នែកសេដ្ឋកិច្ច ចំពោះសហគមន៍ដែលមាន របាក់ចំណូលទាប ។ គណៈកម្មការអភិវឌ្ឍន៍សេដ្ឋកិច្ច បានបង្កើត ផែនការន េះ ដោយផ្អែកលើ ការស្រាវជ្រាវថ្មី លក្ខណៈទូលំទូលាយ ការចូលរួម របស់ អ្នកឯកទេសឧស្សាហកម្ម ការពិភាក្សាជាសាធារណៈ ជាមួយនិយោជិតក្នុងទីក្រុង ទស្សនៈរបស់ មេដឹកនាំសហគមន៍ និងម្ចាស់អាជីវកម្ម និងការពិភាក្សា យ៉ាងផុសផុល របស់សមាជិកគណៈ កម្មការ ។ ផែនការនេះ មិនបានបង្ហាញ ពីចុងបញ្ចប់នៃការងាររបស់គណៈអភិបាលក្រុង និងគ ណៈកម្មការនោះទេ ។ ជាការពិត ផែនការនេះ មានតួនាទីជា "ការអំពាវនាវឱ្យធ្វើសកម្មភាព" សម្រាប់ការស្រាវជ្រាវបន្ថែម ការចូលរួមពីសហគមន៍ និងការពិភាក្សា ដើម្បីស្វែងរកយុទ្ធសាស្រ្ត គោលនយោបាយ និងកម្មវិធី ឱ្យបានកាន់តែជាក់លាក់ថែមទៀត ដើម្បីលើកកម្ពស់ឱកាសសេដ្ឋ កិច្ច នៅទូទាំងទីក្រុង ។

ពួកយើងសង្ឃឹមថា ផែនការនេះ បម្រើជាកត្តាលីករ ជម្រុញការពិភាក្សា ជាបន្ត និងថ្មីៗ ទៀត ព្រមទាំងកិច្ចសហប្រតិបត្តិការ របស់ភាគីពាក់ព័ន្ធ ដែលយល់ថា ការបង្កើតឱកាសសេដ្ឋ កិច្ចនេះ ជាកិច្ចការដ៏សំខាន់ ដើម្បីលើកកម្ពស់ គុណភាពជីវិតរស់នៅ ក្នុងទីក្រុងនេះ ។ ពួក យើងលើកទឹកចិត្តឱ្យ ដៃគូវិស័យសាធារណៈ ដៃគូវិស័យឯកជន ដៃគូវិស័យអប់រំ និងដៃគូវិស័យ មិនរកប្រាក់ចំណេញទាំងអស់ ចូលរួមដោយផ្ទាល់ ក្នុងការអភិវឌ្ឍន៍វិស័យសេដ្ឋកិច្ចនេះ ដើម្បីប្រើ ប្រាស់មធ្យោបាយថ្មីៗ ក្នុងការជំរុញកិច្ចសហការប្រកបដោយការច្នៃប្រឌិត ។ ហើយ ពួកយើងក៏ សង្ឃឹមយ៉ាងមុតមាំថា ភាពជាដៃគូវិស័យសេដ្ឋកិច្ចថ្មីនេះនឹងលើកកម្ពស់ការចូលរួមរបស់ទីក្រុង នៅក្នុងកិច្ចខិតខំប្រឹងប្រែង កម្រិតតំបន់ កម្រិតរដ្ឋ និងកម្រិតសកលលោក ដែលនឹងនាំមក នូវ ការវិនិយោគ និងឱកាសការងារថ្មីៗ ជាច្រើន មកកាន់ទីក្រុងឡុងប៊ិច ផងដែរ ។

ពិតណាស់ ការងើបឡើងជាថ្មី របស់ទីក្រុងឡុងប៊ិច ពិតជាមានភាពរស់រវើក និងឈាន ឆ្ពោះទៅមុខជានិច្ច ។ ដោយការធ្វើការងាររួមគ្នា ទីក្រុងឡុងប៊ិចអាចនឹងត្រូវបានចាត់ទុកជា គំរូមួយ និងជាទីក្រុងឈានមុខមួយ តំណាងឱ្យ ឱកាសសេដ្ឋកិច្ច និងកិច្ចសហប្រតិបត្តិការសហ គមន៍ ដែលផ្តល់ អត្ថប្រយោជន៍ជាច្រើនដល់ ប្រជាពលរដ្ឋ អាជីវករ វិនិយោគិន និងយុវជន ។

**Randal Hernandez, Chairman**

# សេចក្តីថ្លែងអំណរគុណ

## MAYOR AND CITY COUNCIL

Dr. Robert Garcia, Ed.D., Honorable Mayor
Rex Richardson, Vice Mayor and Councilmember, 9th District
Lena Gonzalez, Councilwoman, 1st District
Jeannine Pearce, Councilwoman, 2nd District
Suzie Price, Councilwoman, 3rd District
Daryl Supernaw, Councilman, 4th District
Stacy Mungo, Councilwoman, 5th District
Dee Andrews, Councilman, 6th District
Roberto Uranga, Councilman, 7th District
Al Austin, Councilman, 8th District

## OFFICE OF THE CITY MANAGER

Patrick H. West, City Manager
Tom Modica, Assistant City Manager
Kevin Jackson, Deputy City Manager
Public Affairs Team
Long Beach Innovation Team
Office of Sustainability

## ECONOMIC DEVELOPMENT COMMISSION

Randal Hernandez, Chair
Becky Blair, Vice Chair
Cyrus Parker-Jeannette, Commissioner
Blair Cohn, Commissioner
Bobby Olvera Jr., Commissioner
Jacob Flores, Commissioner
Dr. Jessica Schumer, Commissioner
Leah Goold-Haws, Commissioner
Michelle Molina, Commissioner
Ralph Holguin, Commissioner
Walter Larkins, Commissioner
Frank Colonna, Former Commissioner
Kristi Allen, Former Commissioner
Lincoln Bauer, Former Commissioner

## CITY ATTORNEY'S OFFICE

Amy Webber, Deputy City Attorney
Gary Anderson, Principal Deputy City Attorney

## DEPARTMENT OF DEVELOPMENT SERVICES

Amy J. Bodek, Former Director
Oscar Orci, Deputy Director
Linda F. Tatum, Planning Bureau Manager
Carrie Tai, Current Planning Officer
Christopher Koontz, Advance Planning Officer
Truong Huynh, General Superintendent
Alem Hagos, Grants Administration Officer
Elizabeth Salcedo, Administrative Analyst
Communications Division

## DEPARTMENT OF ECONOMIC DEVELOPMENT

John Keisler, Director
Sergio Ramirez, Deputy Director
Nick Schultz, Executive Director, PGWIN
Seyed Jalali, Economic Development Officer
Jim Fisk, Project Manager (retd.)
Bob Mossler, Project Analyst
Eric Romero, Development Project Manager
Jessica Dela Rosa, Secretary

## DEPARTMENT OF FINANCIAL MANAGEMENT

John Gross, Director
Lea Eriksen, Assistant Finance Director
Brett Yakus, Business Services Officer

## DEPARTMENT OF PUBLIC WORKS

Craig Beck, Director

## COMMUNITY ORGANIZATIONS

Belmont Shore Business Association
Bixby Knolls Business Improvement Association
Building Healthy Communities: Long Beach
California State University, Long Beach
Council of Business Associations
Downtown Long Beach Alliance (DLBA)
Emissary Media Group
Long Beach Chamber of Commerce
Long Beach City College, College of Advancement and Economic Development (CAED)
Long Beach Convention and Visitors Bureau
Los Angeles Economic Development Corporation
Magnolia Industrial Group
Port of Long Beach
The Nonprofit Partnership
Uptown Business District

## STUDY SESSION PARTICIPANTS

Brett Yakus, Business Services Officer, City of Long Beach
Bryan Sastokas, Former Director of Technology & Innovation, City of Long Beach
Carrie Tai, Current Planning Officer, City of Long Beach
Chad Van Alstine, VP, The Grupe Company
Christopher Koontz, Advance Planning Officer, City of Long Beach
Jan Van Dijs, Urbana Development
Jane Close Conoley, President, California State University, Long Beach
Kent Peterson, VP, P2S Engineering, Inc.
Kimberly Ritter-Martinez, Economist, Los Angeles Economic Development Corporation
Kraig Kojian, President and CEO, DLBA
Leah Goold-Haws, Director of Global Trade and Logistics Long Beach City College
Lisa Callamaro, Literary Agent
Lou Anne Bynum, Executive VP, Long Beach City College CAED
Michelle Molina, Managing Partner, Millworks
Noel Hacegaba, Managing Director of Commercial Operations, POLB
Oscar Orci, Deputy Director of Development Services, City of Long Beach
Rodric David, CEO, Thunder Studios
Tom Bowman, President, Bowman Change, Inc.
Truong Huynh, General Superintendent, City of Long Beach
Will Pomerantz, VP Special Projects, Virgin Galactic

## SPECIAL THANKS

Bloomberg Philanthropies
Harrison Huynh, Designer
Isaul Berenguer, Designmatters Fellow
Jack Smith, Resident
Lauren Vargas, Director of Innovation Delivery & Special Projects, Mayor's Office
Ryan Murray, Former Innovation Deputy, Mayor's Office

# មាតិកា


ចក្ខុវិស័យ ........ 6

កម្លាំងចលករ នៃកំណើន ........ 7

បរិយាប័នផ្នែកសេដ្ឋកិច្ច ........ 8

ការអភិវឌ្ឍការងារ និងកម្លាំងពលកម្ម ........ 9

បរិបទនៃការអភិវឌ្ឍ ........ 10

ជំនួយផ្នែកអាជីវកម្ម ........ 11

គុណភាពជីវិតរស់នៅ ........ 13

ភាពជាអ្នកដឹកនាំ ផ្នែកសេដ្ឋកិច្ច និងកិច្ចសហប្រតិបត្តិការ ........ 15

ដំណើរការអនុវត្តន៍ ........ 17

ឯកសារយោង និង ខ្លឹមសារសម្រង់ ........ 18

# ចក្ខុវិស័យ



ផែនការអភិវឌ្ឍន៍វិស័យសេដ្ឋកិច្ចនេះ និងបរិយាយចក្ខុវិស័យរយៈពេល10ឆ្នាំ របស់ទីកុម្រងឡុងប៊ិច ក្នុងការប្រែក្លាយខ្លួនជា “ទីកុម្រងប្រកបដោយឱកាសស ម្រាប់និយោជិត វិនិយោគិន និងសហគ្រិន”។

- សម្រាប់ទីក្រុងឡុងប៊ិច និងដៃគូដែលជា ប្រជាពលរដ្ឋ ផែនការនេះមានតួនាទីជាកត្តា លីករ ជំរុញឱ្យមានកិច្ចសហការគ្នាធ្វើការ ទទួលស្គាល់ លក្ខណៈបុរេសកម្ម និងស្វែងរក ដំណោះស្រាយ ប្រកបដោយការប្តេជ្ញាចិត្តខ្ពស់ ដើម្បីដោះស្រាយ បញ្ហាប្រឈម ផ្នែកសេដ្ឋកិច្ច សង្គម និងឱកាសនានាក្នុងទីក្រុង ។
- សម្រាប់និយោជិត ទីក្រុងឡុងប៊ិច នឹងក្លាយ ជាទីក្រុងមួយ ដែលពួកយើងរួមគ្នាបង្កើតឱ កាសការងារជាច្រើន ដែលមានប្រាក់បៀវត្ស ន៍កាន់តែខ្ពស់ លើសពីសេចក្តីត្រូវការ ជាមូល ដ្ឋាន ។
- សម្រាប់វិនិយោគិន ទីក្រុងឡុងប៊ិច នឹង បង្កើតឱ្យមាន បរិយាកាស □អាចធ្វើបាន□ មួយ ដែលពួកគេអាចធ្វើការប្រកួតប្រជែងបាន យ៉ាងសកម្ម ដើម្បីបង្កើតឱ្យមានឧត្តម ភាពដាច់គេ ក្នុងការបង្កើតឱកាសសេដ្ឋកិច្ច សម្រាប់ពាណិជ្ជកម្ម និងសហគមន៍ ។
- សម្រាប់សហគ្រិន ទីក្រុងឡុងប៊ិច នឹងបង្កើត ឱ្យមាន ប្រព័ន្ធអេកូឡូស៊ី ប្រកបដោយការច្នៃ ប្រឌិតមួយ ដែលផ្តល់ជាមូលដ្ឋានរឹងមាំ សម្រាប់ភាពជោគជ័យ ចាប់ពីពេលចាប់ផ្តើម អាជីវកម្ម រហូតដល់អាជីវកម្មមានការរីក ចម្រើនទៅមុខទៀត ។
- សម្រាប់ប្រជាពលរដ្ឋ ទីក្រុងឡុងប៊ិច នឹង ក្លាយជាទីក្រុងមួយ ដែលប្រជាពលរដ្ឋទាំង អស់ អាចទទួលបានឱកាស បង្កើតអាជីវ កម្ម ឱកាសរីកចម្រើន បង្កើតឥទ្ធិពលជា វិជ្ជមាន នៅទីកន្លែងដែលពួកគេរស់នៅ ។

## គោលដៅ គោលដៅ គោលដៅ

ដើម្បីសម្រេចឱ្យបានចក្ខុវិស័យនេះ គណៈកម្ម ការអភិវឌ្ឍន៍សេដ្ឋកិច្ច ផ្តល់អនុសាសន៍ ឱ្យសម្រេច គោលដៅនានា ដូចខាងក្រោមនេះ ៖

- កសាងទីក្រុងឡុងប៊ិច ឱ្យក្លាយទៅជាទីក្រុង ឈានមុខគេ ក្នុងការពង្រីក ការរក្សាឱ្យស្ថិត ស្ថេរ និងការរីកចម្រើន ក្នុងវិស័យអប់រំ និង ពាណិជ្ជកម្ម ។
- ធានាឱ្យបានថា សេដ្ឋកិច្ចទីក្រុងឡុងប៊ិច ផ្តល់ឱកាសការងារ គួរជាទីពេញចិត្ត យ៉ាង ហោចណាស់មួយ សម្រាប់ប្រជាពលរដ្ឋ និង សិស្ស-និស្សិត គ្រប់រូប រស់នៅក្នុងទីក្រុងឡុង ប៊ិច ដែលចង់បានការងារធ្វើ ។
- បង្កើត វប្បធម៌ពលរដ្ឋ និងសេដ្ឋកិច្ច ដែលផ្តល់លទ្ធភាពទទួលបាន ធនធាន និងទីផ្សារ ដែល ចាំបាច់ សម្រាប់ការចាប់ផ្តើមអាជីវកម្ម និងរក្សាអាជីវកម្ម ឱ្យស្ថិតស្ថេរ ដល់សហ គ្រិន គ្រប់រូប ក្នុងទីក្រុងឡុងប៊ិច ។
- ធានាឱ្យបាន តាមរយៈសកម្មភាពដែលធ្វើឱ្យ ទីក្រុងឡុងប៊ិច ត្រូវបានគេទទួលស្គាល់ថា ជា ទីក្រុងមួយ ក្នុងចំណោមទីក្រុង ដែលគួរអោយចង់រស់នៅជាងគេ មានភាពច្នៃប្រឌិត ជាងគេ និងបរិយាប័នខ្ពស់ជាងគេ ក្នុង ពិភពលោក ។

## វិស័យសំខាន់ៗ ក្នុងផែនការ

1. កម្លាំងចលករ នៃកំណើន
2. បរិយាប័នផ្នែកសេដ្ឋកិច្ច
3. ការអភិវឌ្ឍការងារ និងកម្លាំងពលកម្ម
4. ជំនួយផ្នែកអាជីវកម្ម
5. បរិបទនៃកាអភិវឌ្ឍន៍
6. គុណភាពជីវិតរស់នៅ
7. ភាពជាអ្នកដឹកនាំ ផ្នែកសេដ្ឋកិច្ច និងកិច្ច សហប្រតិបត្តិការ

# កម្លាំងចលករ នៃកំណើន




បណ្តុះនិងពង្រឹងចង្កោមឧស្សាហកម្មដែល បង្កើតឡើងរួចនិងវិស័យនានាដែលកំពុង លេចឡើង។

វត្ថុបំណង ៖

- បង្កើន ចំនួនអាជីវកម្ម និងការងារ ក្នុង ចង្កោមឧស្សាហកម្មសំខាន់ៗ ។
- បង្កើន ចំនួនអាជីវកម្ម និងការងារ ក្នុង ឧស្សាហកម្មសម្រាប់ពាណិជ្ជកម្ម ។
- បង្កើន សមត្ថភាពស្រាវជ្រាវ និងភាពពាក់ ព័ន្ធ ដោយវាស់ស្ទង់ដឹងបាន តាមរយៈប៉ាតង់ ដែលបាន អនុញ្ញាតឱ្យ ។
- បង្កើន សកម្មភាពទេសចរណ៍ ដោយវាស់ស្ទង់ តាមរយៈចំណូលពន្ធ លើសិទ្ធកានកាប់ បណ្តោះអាសន្ន ។

អនុសាសន៍ ៖

1. បើកកិច្ចប្រជុំតុមូលសម្រាប់ចង្កោមឧស្សាហកម្មដើម្បីបង្កើតវិធីសាស្រ្តសម្រាប់តាមដានត្រួតពិនិត្យនិងបង្កើតយុទ្ធសាស្រ្តនានាដែលបង្កើនចំនួនក្រុមហ៊ុននៅក្នុងវិស័យនាំមុខគេ និងវិស័យនានាដែលកំពុងលេចឡើង។
2. បង្កើតភាពជាដៃគូផ្នែកនវានុវត្តន៍និងបច្ចេកវិទ្យា ដែលអាចដឹកនាំដោយសាកលវិទ្យាល័យរដ្ឋកាលីហ្វ័រញ៉ា, មហាវិទ្យាល័យឡុងប៊ិច និងទីក្រុងឡុងប៊ិច, ដើម្បីគាំទ្រដល់ការស្រាវជ្រាវ, ការបង្កើតអាជីវកម្ម, និងការអភិវឌ្ឍចង្កោមឧស្សាហកម្មដែលកំពុងលេចឡើង។
3. ផ្តល់អំណាចដល់ដៃគូ តាមរយៈការសម្របសម្រួល កាន់តែប្រសើរឡើង ដើម្បីទាក់ទាញ និងអភិវឌ្ឍអាជីវកម្មខ្នាតតូចដែលគាំទ្រដល់វិស័យឧស្សាហកម្មសំខាន់ៗ ។
4. ផ្តល់អាទិភាព ដល់ការវិនិយោគ លើឧស្សាហ កម្ម និងវិស័យនានា ដែលផ្តល់នូវការងារ មានប្រាក់បៀវត្សន៍ខ្ពស់ ។
5. ជួយលើកស្ទួយសកម្មភាពសហគ្រិន តាមរយៈ ការបង្កើនការទទួលបានការណែនាំ ពីសហគ្រិនដូចគ្នា និងពង្រីកឱកាសបណ្តុះបណ្តាល សម្រាប់សិស្ស-និស្សិត ដែលចាប់អារម្មណ៍ ក្នុងការចាប់ផ្តើមដំណើរការអាជីវកម្មផ្ទាល់ខ្លួន ។
6. ពង្រឹងជំនួយគាំទ្រដល់សហគ្រិនភាពតាមរយៈស្ថាប័នធនធាន និងកម្មវិធីគាំទ្រនានា ជាលក្ខណៈបណ្តាញផ្លូវការ ។
7. បង្កើតយុទ្ធសាស្រ្ត ដើម្បីផ្សព្វផ្សាយ អំពីឱកាសវិនិយោគ ក្នុងទីក្រុង ទៅដល់ម្ចាស់ពាណិជ្ជកម្មនៅខាងក្រៅ ដែលមកចូលរួមសន្និបាតព្រឹត្តិការណ៍ពិសេសៗ និងនៅតំបន់កំសាន្តនានា ។
8. ធ្វើការវាយតម្លៃជាបន្តលើឱកាសធ្វើការវិ និយោគនិងជំរុញភាពគួរឱ្យប្រាថ្នាចង់បាន របស់មជ្ឈមណ្ឌលសន្និសិទនិងការកំសាន្តឡុងប៊ិច។
9. បង្កើតយុទ្ធសាស្រ្តបង្កើនចំណូលពន្ធលើសិទ្ធកាន់កាប់បណ្តោះអាសន្ន និងចំណូលពាក់ព័ន្ធនឹងវិស័យទេសចរណ៍ក្នុងទីក្រុង ។
10. ធ្វើការស្វែងរកអភិវឌ្ឍនិងអនុវត្តផែនការនានា ដើម្បីប្រើប្រាស់មាត់ទឹកទន្លេ ឬសមុទ្រ ជាកត្តាជម្រុញសេដ្ឋកិច្ច សម្រាប់វិស័យដំណើរ កំសាន្ត បដិសណ្ឋារកិច្ច និងការលក់រាយ ។
11. លើកកម្ពស់ការអភិវឌ្ឍថាមពលកកើតឡើងវិញ និងបច្ចេកវិទ្យាឧស្ម័នផ្ទះកញ្ចក់ ដែល កំពុងរីកដុះដាលឡើង ។

# បរិយាប័ន្នសេដ្ឋកិច្ច



## បង្កើនលទ្ធភាពទទួលបាន កាលានុវត្តភាពសេដ្ឋកិច្ច ក្នុងសហគមន៍មានចំណូលទាប ដើម្បីជំរុញ សមធម៌ផ្នែកសេដ្ឋកិច្ច ។

### វត្ថុបំណង ៖

- បង្កើនចំនួនអាជីវកម្មដែលកាន់កាប់ដោយជនជាតិភាគតិចនិងស្ត្រី។
- បង្កើនធនធានដើមទុនមិនមែនតាមបែបប្រពៃណីទុកសម្រាប់អាជីវកម្មដែលកាន់កាប់ដោយជនជាតិភាគតិចនិងស្ត្រី។
- បង្កើនការវិនិយោគក្នុងច្រករបៀងអាជីវកម្មដែលមានចំណូលទាប។
- បង្កើនភាគរយដែលគណៈអភិបាលក្រុង ចំណាយលើអាជីវកម្ម នៅមូលដ្ឋានដោយផ្តោតលើអាជីវកម្មដែល កាន់កាប់ដោយជនជាតិភាគតិចនិងស្ត្រី។
- បង្កើនអក្ខរកម្មផ្នែកហិរញ្ញវត្ថុនិង ឱកាសស្វែងរកទ្រព្យសម្បត្តិសម្រាប់ មនុស្សវ័យក្មេងនិងគ្រួសារខ្សត់ខ្សោយ ។
- កាត់បន្ថយគម្លាតនៃភាពគ្មានចំណេះដឹងផ្នែកកុំព្យូទ័រនិងអ៊ីនធឺណិតសម្រាប់គ្រួសារដែលមានចំណូលទាប។

### អនុសាសន៍ ៖

1. បង្កើតផែនការនិងយុទ្ធសាស្ត្រដើម្បីទាក់ទាញការវិនិយោគ និងលំអរច្រករបៀងអាជីវកម្ម លើកទឹកចិត្តដល់ការបង្កើតនិង ការរក្សាអាជីវកម្មឱ្យនៅស្ថិតស្ថេរនិងជួយគាំទ្រដល់ការបង្កើតការងារ ក្នុងសហគមន៍ដែលមានចំណូលទាប ។
2. ពង្រឹងសមត្ថភាពប្រកួតប្រជែងសម្រាប់និយោជិត និងម្ចាស់អាជីវកម្មខ្នាតតូច ក្នុងតំបន់ដែលមានចំណូលទាប តាមរយៈ ការផ្តល់ការបណ្តុះបណ្តាលការងារ ធនធានសម្រាប់អាជីវកម្មខ្នាតតូច ជំ នួយបច្ចេ កទេស និ ងគ្រឿងលើ កទឹ កចិ ត្តទៅកាន់ តំបន់ទាំងនេះដោយផ្ទាល់ ។
3. ប្តេជ្ញាក្នុងការទទួលអនុវត្តប្រតិបត្តិអភិវឌ្ឍន៍អាជីវកម្មប្រកបដោយសមធម៌ ពីទីក្រុងដទៃទៀតនៅទូទាំងប្រទេស ។
4. ធ្វើការប៉ាន់ប្រមាណ ពីតម្លៃនៃការបង្កើត តំបន់ស្តារឡើងវិញនិងកែលម្អសហគមន៍ ឬ តំបន់ផ្តល់ហិរញ្ញប្បទានដើម្បីហេដារចនាសម្ព័ន្ធប្រសើរឡើង ក្នុងតំបន់មានចំណូលទាប ។
5. ចាប់ដៃគូជាមួយអ្នកផ្តល់ប្រាក់កម្ចីនានាដើម្បីសម្រេចឱ្យបាន លទ្ធភាពទទួលបានមូលទុនកាន់តែទូលំទូលាយឡើង សម្រាប់ម្ចាស់អាជីវកម្មដែលមានពណ៌សម្បុរខុសៗ គ្នា និងដែលជាស្ត្រីនៅក្នុងសហគមន៍មានចំណូលទាប ។
6. ធ្វើការជាមួយសាប៉័នធនាគារនិងស្ថាប័នអប់រំដើម្បីផ្តល់វគ្គបណ្តុះបណ្តាល អំពីចំណេះដឹងផ្នែកហិរញ្ញវត្ថុដល់និវាសនជននិងសិស្សនៅក្នុងតំបន់ ក្រីក្រដែលមានចម្រុះជាតិសាសន៍/ជាតិពិន្ទុកម្រិតខ្ពស់ ។
7. កំណត់ឱកាសនានាក្នុងការបង្កើនលទ្ធភាពទទួលបានសេវាធនាគារ បែបប្រពៃណីនៅទីក្រុងឡុងប៊ិច ភាគខាងលិចនិងទីក្រុងឡុងប៊ិច ភាគខាងជើង ។
8. បង្កើតកម្មវិធីបណ្តុះបណ្តាលបច្ចេកវិទ្យា សម្រាប់ម្ចាស់អាជីវកម្មក្នុង សហគមន៍នានាដែលមានចំណូលទាប ។

# ការអភិវឌ្ឍការងារ




ជំរុញការត្រៀមលក្ខណៈ របស់កម្លាំងពលកម្ម និងសមត្ថភាពប្រកួតប្រជែង របស់អាជីវកម្ម តាមរយៈ ការសម្របតាម កិច្ចខិតខំប្រឹងប្រែង អភិវឌ្ឍន៍សេដ្ឋកិច្ច ការបណ្តុះបណ្តាល ការអប់រំ និងភាពជាដៃគូសហគមន៍ ។

វត្ថុបំណង ៖

- បង្កើនចំណូលមធ្យម ក្នុងមនុស្សម្នាក់ៗ នៅ ទីក្រុង ពីមួយឆ្នាំ ទៅមួយឆ្នាំ
- បង្កើនចំនួនការងារ នៅកម្រិតជំនាញ មធ្យម និងកម្រិតជំនាញខ្ពស់ នៅទីក្រុង
- កាត់បន្ថយអត្រាគ្មានការងារធ្វើ
- បង្កើនចំណែកនៃប្រជាជនជាមនុស្សធំពេញវ័យដែលមានការអប់រំកម្រិតក្រោយវិទ្យាល័យ
- បង្កើនចំនួនអ្នកតាំងទីលំនៅ នៅឡុងប៊ិច ដែលនឹងចូលរួមក្នុងប្រព័ន្ធអប់រំ និងបណ្តុះបណ្តាលម្តងទៀត
- បង្កើនចំនួននិស្សិតនៃសាកលវិទ្យាល័យកាលីហ្វញ៉ានៅទីក្រុងឡុងប៊ិចនិង មហាវិទ្យាល័យឡុងប៊ិចដែលរស់នៅនិងធ្វើការកងួទីក្រុងក្រោយបញ្ចប់ការសិក្សា។
- បង្កើនការបណ្តុះបណ្តាលការងារបៃតង (ការងារដែលទាក់ទងនឹងការការពារ និង អភិវឌ្ឍបរិស្ថានដូចជា៖ កសិកម្ម ការងារ ស្រាវជ្រាវ -ល-) និងបង្កើនឱកាសទទួលបាន ការងារធ្វើ

អនុសាសន៍ ៖

1. វិនិយោគ ទៅលើកម្លាំងពលកម្មដែលកំពុងបំពេញការងារដើម្បីបណ្តុះបណ្តាលពួកគេឱ្យឈានទៅរកការងារកម្រិតជំនាញខ្ពស់និងមានប្រាក់ខែច្រើន
2. ជំរុញអត្រាបញ្ចប់ការសិក្សាកម្រិតវិទ្យាល័យអត្រាចុះឈ្មោះចូលរៀនមហាវិទ្យាល័យនិងអត្រាបន្តការសិក្សានៅក្រោយមធ្យមសិក្សា
3. ផ្តល់ការបណ្តុះបណ្តាលអំពីសហគ្រិនភាពនៅគ្រប់កម្រិតនៃការអប់រំ
4. ពង្រីកលទ្ធភាពទទួលបានជំនាញសំខាន់ៗដែលអាចរកការងារបានដែលបានរៀបចំឡើងដើម្បីជំរុញលទ្ធភាពទទួលបានការអប់រំទូទៅនិងបង្កើនអត្រារក្សាកម្មវិធីដ៏ជីថលនៅទីក្រុង
5. ពង្រីកនិងលើកកម្ពស់ឱកាសបណ្តុះបណ្តាលសារជាថ្មីសម្រាប់មនុស្សពេញវ័យតាមរយៈវិស័យសាធារណៈវិស័យឯកជនវិស័យអប់រំនិងវិស័យជំនឿតាមសហគមន៍ក៏ដូចជាប្រព័ន្ធផ្សព្វផ្សាយមជ្ឈមណ្ឌលសហគមន៍និងមជ្ឈមណ្ឌលថែរក្សាមនុស្សចាស់ព្រមទាំងមជ្ឈមណ្ឌលធនធាន
6. លើកកម្ពស់សារៈសំខាន់នៃការបង្កើន លទ្ធភាពទទួលបាន ឱកាសអប់រំសម្រាប់មនុស្សពេញវ័យរួមទាំង ការរៀនសូត្រពេញមួយជីវិត ការបណ្តុះបណ្តាលអំពីបច្ចេកវិទ្យា និងកម្មវិធីនានាតាមសាកលវិទ្យាលយនិងតាម មហាវិទ្យាល័យនៅសហគមន៍ ។
7. បង្កើតយានមួយដើម្បីធ្វើការវាយតម្លៃជាទម្លាប់លើសេចក្តីត្រូវការផ្នែកកម្លាំងពលកម្មនិងឱកាសនានារបស់ឧស្សាហកម្មនិងវិស័យដែលមានកំណើនខ្ពស់ហើយសម្របកម្មវិធីអប់រំទៅតាមនោះនិងបំពេញតាមសេចក្តីត្រូវការរបស់ពួកគេ។
8. សហការជាមួយវិស័យឯកជននិង មហាវិទ្យាល័យឡុងប៊ិចដើម្បីបង្កើតយុទ្ធសាស្ត្ររយៈពេលវែង សម្រាប់បង្កើនឱកាសបណ្តុះបណ្តាលវិជ្ជាជីវៈនៅទូទាំងទីក្រុង ។
9. រួមបញ្ចូលការជួយសែង្វរកការងារឱ្យក្នុង THE LONG BEACH COLLEGE PROMISE (ជាគំនិតផ្តួចផ្តើមមួយដែលពង្រីកការសន្យានៃការអប់រំកម្រិត មហាវិទ្យាល័យដល់សិស្សគ្រប់រូបដែលចូលរៀននៅសាលារៀនទីក្រុងឡុងប៊ិច)។
10. បង្កើតយុទ្ធសាស្ត្រដើម្បីរក្សាទុកនិស្សិតបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យរដ្ឋកាលីហ្វ័រញ៉ា, មហាវិទ្យាល័យឡុងប៊ិចនិងទីក្រុងឡុងប៊ិចឱ្យរស់នៅនិងធ្វើការក្នុងទីក្រុងក្រោយបញ្ចប់ ការសិក្សានោះដោយកាត់បន្ថយ «ការហូរចេញអ្នកចេះ» និងអន្តោប្រវេសន៍ចេញទៅ ក្រៅ។

# បរិបទនៃការអភិវឌ្ឍ



បង្កើតដំណើរការទីក្រុងដែលហាក់សមានប្រសិទ្ធភាពចំណាយ និងមានភាពរលូនដើម្បីទាក់ទាញនិងបង្កើនការវិនិយោគនិងអភិវឌ្ឍន៍នៅក្នុងទីក្រុង។

## វត្ថុបំណង ៖

- កាត់បន្ថយថ្លៃចំណាយនៃការអភិវឌ្ឍនិងចំនួនថ្ងៃនៃការស្នើសុំអនុម័តលើការផ្តល់សិទ្ធកាន់កាប់។
- កាត់បន្ថយអត្រាទំនេរនៃទីកន្លែងពាណិជ្ជកម្មដែលមិនមែនជាលំនៅដ្ឋាន។
- បង្កើនការវិនិយោគលើអចលនទ្រព្យនៅទូទាំងទីក្រុង។

## អនុសាសន៍ ៖

1. លើកកម្ពស់ការអប់រំអំពីដំណើរការអភិវឌ្ឍតម្លាភាពនិងវប្បធម៌នៃកិច្ចសហការគ្នារវាងមន្ត្រីក្រុងនិងអតិថិជនដើម្បីបង្កើតបទពិសោធន៍នៃការអភិវឌ្ឍអចលនទ្រព្យមួយដែលអាចជឿជាក់បាន។
2. ប្រមូលផ្តុំក្រុមការងារជ្រើសរើសទីតាំងអភិវឌ្ឍសេដ្ឋកិច្ចដើម្បីរៀបចំសិក្ខាសាលាស្តីពីការអភិវឌ្ឍនិងវិនិយោគ ដើម្បីកំណត់ដំណើរការអភិវឌ្ឍប្រកបដោយតម្លាភាពមួយសម្រាប់កាលានុវត្តភាពអភិវឌ្ឍន៍ពាក់ព័ន្ធនឹងប្រភេទអចលនទ្រព្យជាក់លាក់ ។
3. ធ្វើទំនើបកម្មលើបទប្បញ្ញត្តិស្តីពីការប្រើប្រាស់ដីធ្លីសិទ្ធិកាន់កាប់និងដំណើរការផ្តល់ការអនុញ្ញាតដើម្បីឆ្លុះបញ្ចាំងពីកាលានុវត្តភាពសេដ្ឋកិច្ចថ្មីៗ និងបញ្ច្រាបដំណើរការអភិវឌ្ឍ។
4. បញ្ចូល "ធាតុអភិវឌ្ឍន៍សេដ្ឋកិច្ច" មួយទៅក្នុងផែនការទូទៅរបស់ទីក្រុង និងផ្សារភ្ជាប់ទៅនឹងធាតុផ្សំនៃការប្រើប្រាស់ដីធ្លីដែលបានកែលម្អរួច ដើម្បីកំណត់ឱ្យបានច្បាស់ពីកាលានុវត្តភាពនានាសម្រាប់ពាណិជ្ជកម្ម ឧស្សាហកម្មនិងការវិនិយោគប្រភេទផ្សេងៗទៀត។
5. ចាប់ដៃគូជាមួយគណៈកម្មការផែនការដើម្បីវាយតម្លៃលើលក្ខខណ្ឌតម្រូវសម្រាប់ចំណត ដែលបង្ករជាឧបសគ្គដល់ការអភិវឌ្ឍនិងកំណើនអាជីវកម្ម ។
6. ធ្វើការវាយតម្លៃលើហេតុប៉ះពាល់សេដ្ឋកិច្ចពីបទបញ្ញត្តិថ្មីៗដែលអាចប៉ះពាល់ដល់ការអភិវឌ្ឍអាជីវកម្មនិងអចលនទ្រព្យទាំងមុន និងក្រោយការអនុវត្ត។
7. ផ្តល់ហេដ្ឋារចនាសម្ព័ន្ធ និងសេវាសាធារណៈ ប្រកបដោយភាពទាក់ទាញ និងមានគុណ ភាពខ្ពស់ ដើម្បីទាក់ទាញការវិនិយោគ និង ការអភិវឌ្ឍពីវិស័យឯកជន ។
8. បង្កើតកម្មវិធី និងព្រឹត្តិការណ៍នានា ដែលជំរុញឱ្យមានអន្តរកម្ម រវាងមន្ត្រីក្រុង សហគមន៍អចលនទ្រព្យលក្ខណៈពាណិជ្ជកម្មនិងវិនិយោគិន ប្រកបដោយសក្តានុពល ។
9. ប្រើប្រាស់ឧបករណ៍តាមអ៊ីនធឺណែតដើម្បីផ្តល់លទ្ធភាពទទួលបានកាលានុវត្តភាពនៃការអភិវឌ្ឍ/ការអភិវឌ្ឍឡើងវិញជាសាធារណៈនិងជាលក្ខណៈឯកជនឱ្យបានទាន់ពេលវេលា។



## បង្កើតប្រព័ន្ធសេដ្ឋកិច្ច ប្រកបដោយការគាំទ្រមួយ ដែលអាចផ្តល់មាគ៌ាលូតលាស់ ដែលអាចទុក ចិត្តបាន ដល់ សហគ្រិន ដើម្បីចាប់ផ្តើម និងអភិវឌ្ឍ អាជីវកម្មរបស់ពួកគាត់ បានប្រកបដោយភាព ជឿជាក់ ។

### វត្ថុបំណង ៖

- កាត់បន្ថយថ្លៃចំណាយក្នុងការធ្វើអាជីវកម្ម និងចំនួនថ្ងៃនៃការស្នើសុំអាជ្ញាបណ្ណអាជីវកម្ម ។
- បង្កើនចំនួនអាជ្ញាបណ្ណអាជីវកម្ម ។
- បង្កើន ភាពអាចរកបាន និងលទ្ធភាពទទួល បាន ការប្រើប្រាស់អ៊ីនធឺណេត ក្នុងល្បឿនលឿន ។
- អភិវឌ្ឍទីក្រុងឡុងប៊ិចឱ្យទៅជាទីក្រុងដែលទាក់ទាញ ការវិនិយោគខ្លាំងបំផុតមួយនៅក្នុងរដ្ឋ ។
- បង្កើនចំនួន និងទំហំកម្ចីអាជីវកម្ម ខ្នាតតូច ដែលមានកិច្ចធានា ។
- ជំរុញប្រតិបត្តិសកម្មភាពអាជីវកម្ម ដែលគាំទ្រ និរន្តរភាពបរិស្ថាន ។

### អនុសាសន៍ ៖

1. អភិវឌ្ឍតំបន់ការកែលអរអាជីវកម្មថ្មីៗនិងរក្សា ឱ្យបាននូវចរន្តផ្តល់មូលនិធិប្រកបដោយនិរន្តរ៍ភាពសម្រាប់តំបន់កែលំអរអាជីវកម្មដែលមានស្រាប់។
2. ពង្រឹង តំបន់កែលំអអាជីវកម្មនានា ដើម្បីគាំទ្រ ការពង្រីកអាជីវកម្ម ការរក្សាឱ្យអាជីវកម្ម នៅ ស្ថិតស្ថេរ  និងកិច្ចខិតខំប្រឹងប្រែងទាក់ទាញ បន្ថែមទៀត នៅឡុងប៊ិច។
3. បង្កើតមជ្ឈមណ្ឌលច្រើនកន្លែងដែលមានធនធានសម្រាប់ជំនួយ បច្ចេកទេស ហិរញ្ញវត្ថុ និងជំនួយផ្នែកច្បាប់ សម្រាប់អាជីវកម្មខ្នាតតូចនៅទូទាំងទីក្រុង។
4. បង្កើតកម្មវិធីអភិបាលអាជីវកម្មខ្នាតតូចដែលនឹងផ្តល់ការសេវាប្រឹក្សាសេវាតម្រង់ទិសផ្នែករដ្ឋបាលចំពោះដំណើរការរបស់ក្រុង និងសេវាអប់រំ អំពីសេវានានារបស់ក្រុងដើម្បីបញ្ជ្រាបដំណើរការចាប់ផ្តើមអាជីវកម្ម។
5. លើកទឹកចិត្ត អាជីវកម្មនៅមូលដ្ឋាន ឱ្យដាក់ ពាក្យស្នើសុំ កិច្ចសន្យាជាមួយក្រុង ដោយបង្កើន ឱកាសធ្វើលទ្ធកម្ម លក្ខណៈអំណោយផល ដល់ អាជីវកម្ម នៅទីក្រុងឡុងប៊ិច។
6. បង្កើតផែនការ ក្នុងការកែលំអរ លទ្ធភាពទទួល បាន អ៊ីនធឺណេតល្បឿនលឿន ដើម្បីជួយសម្រួល ដល់ ការអភិវឌ្ឍន៍អាជីវកម្ម និងកំណើនការងារ ។
7.  ធ្វើឱ្យប្រសើរឡើង នូវចំណាត់ថ្នាក់ទីក្រុង ចំពោះ “ការស្ទង់មតិអំពីថ្លៃចំណាយ ក្នុងការធ្វើអាជីវកម្ម” ដែលបានជ្រើសរើសរួចដោយធ្វើការវាយ តម្លៃ លើសមត្ថភាពប្រកួតប្រជែងរបស់ទីក្រុងនេះជាមួយបណ្តាទីក្រុងនានា ដែលស្រដៀងគ្នា តាមរយៈ ពន្ធអាជីវកម្ម ពន្ធអ្នកប្រើប្រាស់សេវា សាធារណៈ របស់ទីក្រុង អត្រាពន្ធលើការលក់ និងថ្លៃផ្សេងៗ ទៀត ។
8. បង្កើតវេទិកា ដើម្បីតាមដានលំហូរការងារ របស់ សហគ្រិន តាមរយៈដំណើរការចាប់ផ្តើមអាជីវកម្ម ដែលរួមមាន ការផ្តល់អាជ្ញាបណ្ណអាជីវកម្ម ការ អនុញ្ញាតឱ្យប្រើប្រាស់ ដោយមានលក្ខខណ្ឌ កា រអនុញ្ញាតិឱ្យប្រើប្រាស់ លក្ខណៈរដ្ឋបាល និងការ ត្រួតពិនិត្យ ។
9. វិនិយោគទៅលើសេវារបស់ក្រុងលក្ខណៈបុរេសកម្មដែលគាំទ្រដល់ការពង្រីកអាជីវកម្មនិងការរក្សាអាជីវកម្មឱ្យនៅស្ថិតស្ថេរ បង្កើនពន្ធលើការលក់និងប្រាក់ចំណូលពីអាជ្ញាបណ្ណអាជីវកម្ម ហើយគាំទ្រដល់គំនិតផ្តួចផ្តើមអភិវឌ្ឍន៍សេដ្ឋកិច្ចនានា ។
10. សម្រួល និងពង្រឹង ទំនាក់ទំនងរវាងបណ្តាញអង្គ ការគាំទ្រអាជីវកម្ម និងសហគមន៍អចលនទ្រព្យ លក្ខណៈពាណិជ្ជកម្ម នៅមូលដ្ឋាន ដែលមាន ស្រាប់ ។
11. លើកទឹកចិត្ត និងផ្តល់រង្វាន់ ដល់ម្ចាស់អាជីវកម្ម ដែលបានបណ្តាក់ទុន ជាច្រើនប្រភេទ នៅក្រុង ឡុងប៊ិច ។
12. ចាប់ដៃគូជាមួយសាកលវិទ្យាល័យរដ្ឋកាលីហ្វ័រញ៉ា,ឡុងប៊ិច ដើម្បីវាស់វែងលើការយល់ឃើញ អំពីទីក្រុងថាមានលក្ខណៈ អាជីវកម្មមេត្រី, កំណត់រក យុទ្ធសាស្រ្តដើម្បីជំរុញការចូលរួម លក្ខណៈបុរេសកម្មពីសហគមន៍អាជីវកម្មនៅមូលដាន្ឋនិងកែលំអការជឿជាក់លើសេដ្ឋកិច្ចនៅមូលដ្ឋាន។
13. បង្កើនលទ្ធភាពទទួលបានដើមទុន តាមរយៈ ការពង្រីកការផ្សព្វផ្សាយ និងការខិតខំប្រឹងប្រែងធ្វើកិច្ចការទីផ្សារ ទៅដល់ប្រភពមូលធន ដោយលើកកម្ពស់ កម្មវិធីឥណទានក្រុងនានា និងទាក់ទាញអ្នកវិនិយោគទុន និងអ្នកផ្តល់ ប្រាក់កម្ចី សម្រាប់គ្រប់ដំណាក់កាល នៃវដ្តអាជីវកម្ម ។
14. បង្កើតការលើកទឹកចិត្ត ដែលជំរុញឱ្យម្ចាស់អាជីវកម្ម បន្តការអនុវត្តប្រតិបត្តិអាជីវកម្ម ដែលគាំទ្រ និរន្តរភាពបរិស្ថាន ។

# គុណភាពជីវិត



បង្កើនគុណភាពនៃការរស់នៅក្នុងទីក្រុងតាមរយៈការបង្កើត អាជីវកម្ម ការងារ និងការវិនិយោគ ដែលគាំទ្រដល់សេដ្ឋកិច្ចនៅមូលដ្ឋានប្រកបដោយការរីកចម្រើន។

វត្ថុបំណង ៖

- បង្កើនការវិនិយោគ លើយុទ្ធសាស្ត្រដែល បង្កើនសុវត្ថិភាពសាធារណៈ នៅគ្រប់ទីតាំង ក្នុងឡុងប៊ិច ។
- បង្កើនលទ្ធភាពទទួលបានលំនៅដ្ឋាន សម្រាប់ពលករ នៅគ្រប់កម្រិតទីផ្សារ ។
- បង្កើន មធ្យោបាយធ្វើដំណើរសកម្ម និង ជម្រើសមធ្យោបាយធ្វើដំណើរសាធារណៈ នៅ គ្រប់ទីតាំង ក្នុងឡុងប៊ិច ។
- បង្កើនភាគរយកុមារ និងមនុស្សពេញវ័យ ដែលទទួលបានធានារ៉ាប់រងសុខភាព ។
- បង្កើន ផ្ទៃដីសួនច្បារសាធារណៈ ក្នុងប្រជាពលរដ្ឋចំនួន 1,000 នាក់ ដោយផ្តោត លើ តំបន់ ដែល «ខ្វះសួនច្បារ» ។
- បង្កើន ចំណែកចូលរួមបំពេញការងារនៅ ឡុងប៊ិច ពីពលរដ្ឋរស់នៅឡុងប៊ិច ។
- បង្កើនការវិនិយោគលើវិស័យសិល្បៈ ។

អនុសាសន៍ ៖

1. សហការ ជាមួយក្រសួងនានានៅកម្រិតក្រុង និងដៃគូសហគមន៍ ដើម្បីលើកកម្ពស់ សុវត្ថិភាពសាធារណៈ តាមមណ្ឌលការងារ និងតាមច្រករបៀងពាណិជ្ជកម្ម ។
2. អនុវត្តអនុសាសន៍នានា ដូចមានរៀបរាប់ នៅក្នុង របាយការណ៍ក្រុង ឆ្នាំ 2017 ស្តីពី ឧបករណ៍គិច្ចការចំណូល និង ការលើកទឹកចិត្ត សម្រាប់ការសាងសង់លំនៅដ្ឋាន ដែល មានតំលៃសមរម្យ សម្រាប់និយោជិត ។
3. វិនិយោគ លើការអភិវឌ្ឍបន្ថែមទៀត លើហេដ្ឋា រចនាសម្ព័ន្ធដឹកជញ្ជូន ប្រកបដោយសុវត្ថិភាព និងសកម្ម នៅទូទាំងទីក្រុង ។
4. វិនិយោគ ទៅលើ សេវាសម្រាប់អ្នកគ្មាន លំនៅដ្ឋាន ដែលអាចផ្តល់ឱកាសការងារសមរម្យ តាមការសមស្រប សម្រាប់អតីតយុទ្ធជន និងជនគ្មានលំនៅដ្ឋាន ។
5. ផ្សារភ្ជាប់ វិស័យសុខាភិបាល និងវិស័យសុខភាពសាធារណៈ ទៅនឹងយុទ្ធសាស្ត្រនានា ដើម្បីផ្សារភ្ជាប់ពលរដ្ឋទាំងអស់ ដែលរស់នៅឡុងប៊ិច ទៅនឹងសេវាសុខភាព ផ្លូវកាយ និងផ្លូវចិត្ត ។
6. កែលំអគុណភាពខ្យល់នៅក្នុងសង្កាត់ដែលទទួលរងផលប៉ះពាល់ខ្លាំងបំផុតក្នុងទីក្រុងនេះដោយអនុវត្តផែនការ "ទីក្រុងឡុងប៊ីចប៉ែកខាងលិចដែលអាចរស់នៅបាន" ( LIVABLE WEST LONG BEACH PLAN ) ។
7. ។លើកកម្ពស់ ការរស់នៅ ប្រកបដោយសុខ ភាពល្អ ដោយពង្រីកសកម្មភាពកម្សាន្ត និង វាលទីធ្លា នានា ដែលជំរុញឱ្យមានការរស់នៅ លក្ខណៈសកម្ម និងបង្កើនលទ្ធភាពទទួលបាន ជម្រើសចំណីអាហារ ធ្វើឱ្យមានសុខភាពល្អ ។
8. អនុវត្ត យុទ្ធសាស្ត្រអភិវឌ្ឍន៍នានា ដែលកាត់ បន្ថយចំនួនប្រជាពលរដ្ឋធ្វើដំណើរនៅខាង ក្រៅទីក្រុងដើម្បីស្វែងរកការងារ ដោយរក្សា ឱ្យបានតុល្យភាព រវាង ការងារ និងលំនៅ ដ្ឋាន ក្នុងលក្ខណៈល្អប្រសើរឡើង ។
9. បង្កើតនិងអនុវត្តភាពជាដៃគូរវាងវិស័យសាធារណៈនិងវិស័យឯកជន ដើម្បីបង្កើតសោភ័ណ្ឌភាពទីក្រុង ។
10. លើកទឹកចិត្តនិងពង្រីកឱកាសសេដ្ឋកិច្ចដែលជំរុញដោយសេវាកម្មវប្បធម៌និងសិល្បៈរបស់ទីក្រុងដែលសាទរភាពចម្រុះគ្នា។
11. ធ្វើការវាយតម្លៃ លើសេចក្តីត្រូវការ របស់សហគមន៍តន្ត្រីករ នៅមូលដ្ឋាន ដើម្បីកំណត់រក គោលនយោបាយ ដែលអាចជួយពួកគេ ឱ្យអាចសម្រេចបានជោគជ័យ លើបញ្ហា ប្រឈម និងឧបសគ្គ ធំៗ បាន ។



# ភាពជាអ្នកដឹកនាំ ផ្នែកសេដ្ឋកិច្ច និងកិច្ចសហប្រតិបត្តិការ



## ជំរុញដំណោះស្រាយរួមសម្រាប់សហគ្រាសអភិវឌ្ឍសេដ្ឋកិច្ច នៅកម្រិតមូលដ្ឋាន និងកម្រិតតំបន់ដើម្បីពង្រីកកាលានុវត្តភាពធុរកិច្ចនិងការ

### វត្ថុបំណង ៖

- បង្កើនការវិនិយោគ ក្នុងវិស័យឯកជន លើគំនិត ផ្តួចផ្តើម សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច នៅទូទាំង ទីក្រុង ។
- បង្កើតភាពជាដៃគូ ក្នុងវិស័យអប់រំ ដែលផ្តោត ទៅលើអាជីព ដែលមានប្រាក់ឈ្នួលខ្ពស់ និងបណ្តុះ កាលានុវត្តភាពធុរកិច្ចថ្មី ៗ
- បង្កើនការចូលរួម និងភាពជាអ្នកដឹកនាំ របស់ទីក្រុងចំពោះបញ្ហាកម្រិតតំបន់ ដែលមានផលប៉ះពាល់ លើអាជីវកម្មក្នុងក្រុង ។
- ពង្រីកកាលានុវត្តភាពទីផ្សារកម្រិតំបន់ និង កម្រិត អន្តរជាតិសម្រាប់ផលិតផលនិងសេវានានានៅក្នុងក្រុង ។
- បង្កើនវិនិយោគផ្ទាល់ពីបរទេសនិងពាណិជ្ជកម្ម អន្តរជាតិ ។

### អនុសាសន៍ ៖

1. បង្កើតកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍សេដ្ឋកិច្ចរវាងវិស័យសាធារណៈ និងវិស័យឯកជននៅឡុងប៊ិច (LONG BEACH) ដើម្បីផ្សារភ្ជាប់ដៃគូ អន្តរវិស័យសម្រាប់បង្កើនប្រសិទ្ធភាពនៃយុទ្ធសាស្ត្ររក្សាឱ្យបានទាក់ទាញ និងពង្រីកវិសាលភាពធុរកិច្ចដើម្បីបង្កើតមជ្ឈមណ្ឌលស្រាវជ្រាវសេដ្ឋកិច្ច អចិន្ត្រៃយ៍មួយនិងដើម្បីរៀបចំយុទ្ធនាការផ្សព្វផ្សាយពង្រីកទីផ្សារនៅ ទូទាំងទីក្រុង ។
2. ពង្រឹងភាពជាដៃគូ សម្រាប់ការបង្កើតថ្មី និង សហគ្រិនភាព រវាងទីក្រុង គ្រឹះស្ថានអប់រំ និងវិស័យឧស្សាហកម្ម ដើម្បីលើកកម្ពស់ការវិនិយោគ និងកាលានុវត្តភាពសេដ្ឋកិច្ចថ្មីៗ ។
3. បង្កើត កិច្ចសហការផ្នែកលទ្ធកម្ម រវាងវិស័យសា ធារណៈ និងវិស័យឯកជន ដើម្បីបង្កើនកាលានុវត្តភាព នៃការផ្តល់វិញ្ញាបនប័ត្រទទួលស្គាល់ និង ការអភិវឌ្ឍធុរកិច្ច សម្រាប់ក្រុមហ៊ុន នៅមូលដ្ឋាន
4. ពង្រឹងការយល់ដឹងអំពីសេវាកម្មការលើកទឹកចិត្តនិងកម្មវិធីអភិវឌ្ឍន៍ធុរកិច្ចដែលមានស្រាប់នៅក្នុងទីក្រុងតាមរយៈយុទ្ធនាការសម្របសម្រួល ទីផ្សារនៅទូទាំងទីក្រុង ។
5. ផ្តល់ការគាំទ្រយ៉ាងសកម្ម ដល់ការអនុវត្ត ផែនការយុទ្ធសាស្ត្រ ឆ្នាំ 2016-2020 របស់រដ្ឋឡូសអេនជីឡេស (LOS ANGELES) សម្រាប់ការអភិវឌ្ឍ សេដ្ឋកិច្ច ។
6. បង្កើតភាពជាដៃគូ ជាផ្លូវការ ជាមួយ ទីក្រុង និងខោនធី របស់រដ្ឋឡូសអេនជីឡេស (LOS ANGELES) ដើម្បីអភិវឌ្ឍន៍មូលដ្ឋានសេដ្ឋកិច្ចរួម សម្រាប់វាយតម្លៃពី ការប្រកួតប្រជែង កម្រិតតំបន់ ។
7. វាយតម្លៃខ្ពស់ កាសចាប់ដៃគូជាមួយទីកុង្រធំៗ នៅ តំបន់អូរ៉េង (ORANGE COUNTY) សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច និង គំនិតផ្តួចផ្តើមធ្វើទីផ្សាររួមគ្នា។
8. ពង្រឹងតួនាទីភាពជាអ្នកដឹកនាំ របស់ទីក្រុង ក្នុងជំរុញប្រសិទ្ធភាពការងារគោលនយោបាយ និងកម្មវិធី នៅកម្រិតតំបន់ និងកម្រិតរដ្ឋ ដែលបង្កើនកាលានុវត្តភាពធុរកិច្ច និងការងារ នៅទូទាំងតំបន់ ។
9. ដើរតួជាអ្នកដឹកនាំ ដើម្បីសម្រួលកិច្ចការសម្របសម្រួល កម្រិតតំបន់ ដើម្បីសម្រេចបានការវិនិយោគ និងការអភិវឌ្ឍ វិស័យហេដ្ឋារចនាសម្ព័ន្ធ។
10. ចាប់ដៃគូជាមួយ ទីភ្នាក់ងារ កម្រិតតំបន់ ដើម្បី លើកកម្ពស់ ការវិនិយោគដោយផ្ទាល់ពីបរទេស និងការធ្វើពាណិជ្ជកម្ម ។
11. ដោយលើកកម្ពស់ភាពជាដៃគូ របស់កំពង់ផែ ក្នុងកម្រិតជាសកលលោក ដឹកនាំបេសកកម្ម ពាណិជ្ជកម្ម សម្រាប់វិស័យជាក់លាក់ នៅកម្រិត តំបន់ ដើម្បីពង្រីកលទ្ធភាព ចូលទៅកាន់ទីផ្សារ ថ្មីៗ សម្រាប់ក្រុមហ៊ុន នៅមូលដ្ឋាន និងទាក់ទាញ វិនិយោគដោយផ្ទាល់ពីបរទេស មកក្នុងទីក្រុង។

# ដំណើរការអនុវត្តន៍




ការកសាង ផនែការអភិវឌ្ឍន៍សដេ្ឋកិច្ច គឺជាកិច្ចខិតខំប្រឹងប្រងែរួមមួយ ដលែមាន កិច្ចប្រជុំជាសាធារណៈ ចំនួន 26 លើក កិច្ចប្រជុំស្ដាប់ជាលក្ខណៈរូបវន្តបុគ្គល ចំនួន 25 លើក និងការពិភាក្សា ជាមួយ ក្រុមអ្នកជំនាញដលែពាក់ព័ន្ធ ចំនួន 20 ក្រុម ។ វិស័យផ្តោតជាសំខាន់ និងវត្ថុបំណងចម្បងនានា តំណាងឱ្យគោលដៅគោលនយោបាយ ដែលប្រាថ្នាសម្រេចឱ្យបាន ដើម្បីជំរុញទីក្រុង ឱ្យធ្វើដំណើរឆ្ពោះ ទៅកាន់ចក្ខុវិស័យរបស់ខ្លួន ដែលចក្ខុវិស័យនោះគឺ ធ្វើឲ្យទីក្រុងក្លាយជា "ទីក្រុងប្រកបដោយកាលានុវត្តភាពសម្រាប់និយោជិក វិនិយោគិន និងសហគ្រិន "។

ដើម្បីសម្រេចឱ្យបាន វត្ថុបំណងចម្បងសំខាន់ៗ ឆ្ពោះទៅរកចក្ខុវិស័យនេះ ដំណើរការអនុវត្តន៍ ដូច មានរាយបញ្ជាក់ខាងក្រោមនេះ ត្រូវបានផ្តល់អនុសាសន៍ឱ្យគោរពតាម ៖

1. ចែកចាយ ផែនការនេះ ទៅកាន់ក្រុមប្រឹក្សាក្រុង គណៈកម្មការក្រុង មន្ត្រីក្រុង និងដៃគូ នានាហើយលើកទឹកចិត្ត ឱ្យមាន ការសម្រប ទៅតាម គោលដៅ និងវត្ថុបំណងនានា នៃកិច្ចអភិវឌ្ឍសេដ្ឋកិច្ច ។

2. វើការជាមួយមន្ត្រីនិងដៃគូនានារបស់ទីក្រុងដើម្បីរៀបចំ ផែនការការងារសម្រាប់ផែនការមេនេះ ដែលរួមមាន សកម្មភាព និងការវិនិយោគជាក់លាក់ ចំណាយប៉ាន់ ស្មាន និងធនធានហិរញ្ញវត្ថុ ព្រមទាំងពេលវេលាដើម្បីសម្រេចឱ្យបានវត្ថុបំណងសំខាន់ៗទាំងនេះ ។

3. បង្កើត វេទិកាតាមបណ្តាញអ៊ីនធឺណែត ដើម្បីតាមដាន និងរាយការណ៍ អំពីដំណើរវិវត្តន៍ នៃកិច្ចការសម្រេច វត្ថុបំណងសំខាន់ៗ សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច ។

4. បង្កើតផែនការទំនាក់ទំនងដើម្បីលើកកម្ពស់ការយល់ដឹង និងចែកចាយផែនការនេះជាពហុទម្រង់និងពហុភាសាទៅកាន់ សហគមន៍អ្នកស្រាវជ្រាវវិនិយោគិន និងដៃគូឧស្សាហកម្មដើម្បី ឱ្យផែនការនោះបានទៅដល់ដៃក្រុមភាគីពាក់ព័ន្ធផ្សេងៗ គ្នាទាំងអស់ ។

5. ផ្តល់បច្ចុប្បន្នភាព ជាទៀងទាត់ ទៅកាន់គណៈកម្មការអភិវឌ្ឍសេដ្ឋកិច្ច គណៈកម្មាធិការអភិវឌ្ឍសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមប្រឹក្សាក្រុង ។

6. រៀបចំសន្និសីទប្រចាំឆ្នាំ ដែលបង្ហាញពីវឌ្ឍនភាព សម្រេចបានតាមផែនការនេះ ដែលរួមមាន ប័ណ្ណពិន្ទុ ដែលផ្តោតលើសូចនាករ កម្រិតសមត្ថភាពអនុវត្តការងារ សម្រាប់

# ឯកសារយោង & ខ្លឹមសារស្រង់

គណៈកម្មការសូមថ្លែងអំណរគុណ ដល់អ្នកនិពន្ធរបាយការណ៍ និងបទបង្ហាញ ដូចមានបញ្ជាក់ខាង ក្រោមនេះ ដែលត្រូវបានពិនិត្យឡើងវិញ ជាផ្នែកនៃដំណើរការកសាងផែនការនេះឡើង ៖


- Beacon Economics, Economic Development Support Analysis, Part I: Economic Overview, October 18, 2016.
- City of Long Beach Development Services Department, Assessment of Fair Housing, December 2016.
- City of Long Beach Development Services Department, 2018-2022 Consolidated Plan, July 2017.
- City of Long Beach Development Services Department, Livable West Long Beach: The West Long Beach Livability Implementation Plan, August 2015.
- City of Long Beach Development Services Department, 2013-2021 Housing Element, January 7, 2014.
- City of Long Beach Development Services Department, Revenue Tools and Incentives for the Production of Affordable and Workforce Housing, May 2017.
- City of Long Beach Health and Human Services Department, 2016 Strategic Plan for Older Adults, 2016.
- City of Long Beach Office of Sustainability, Sustainable City Action Plan, 2010.
- City of Pasadena, Economic Development Task Force Report, November 2012.
- City of Santa Ana, Economic Development Strategic Plan, July 7, 2016.
- Executive Office of the President, Community-Based Broadband Solutions: The Benefits of Competition and Choice for Community Development and High-Speed Internet Access, January 2015.
- Executive Office of the President, Housing Development Toolkit, September 2016.
- Kleinhenz, Dr. Robert, Economic Development Support Analysis, Part II: Industry Clusters Presentation, December 13, 2016.
- Los Angeles County Economic Development Corporation, Considering the Minimum Wage Policy in the City of Long Beach: Theory, Practice and Potential Implications, February 2016.
- Los Angeles County Economic Development Corporation, OTIS College of Art and Design, 2015 Otis Report on the Creative Economy, November 2015.
- Los Angeles County Economic Development Corporation, 2016-2020 Los Angeles County Strategic Plan for Economic Development, January 2016.
- Music Canada, The Mastering of a Music City: Key Elements, Effective Strategies, and Why It's Worth Pursuing, 2014.
- National League of Cities, 2014 Big Ideas for Small Business Report.
- Public Consulting Group, Pacific Gateway Workforce Investment Network Economic and Demographic Analysis, December 2, 2016.
- Santa Clarita Valley Economic Development Corporation, 2015 Annual Report, December 2015.
- Schultz, Nick. Economic & Demographic Analysis Presentation, Pacific Gateway Workforce Investment Network Economic and Demographic Analysis, October 25, 2016.
- Seattle Economic Development Commission, 10-Year Vision Executive Summary, April 2014.

East Village

Naples

Belmont Heights

Rose Park

Traffic Circle

Alamitos Beach

Bixby Knolls

Grant

Cambodia Town

West Side

Bluff Park


ទីក្រុងឡុងប៊ិច
333 វិថីអូមហាវិថី ។
ឡុងប៊ិច, CA 90802


សូមចូលមើលគេហទំព័រ www.longbeach.gov

facebook.com/CityofLongBeachCA

@LongBeachCity

LONG BEACH Economic Development

This information is available in alternative format by request at 562.570.6099.

For an electronic version of this document, visit our website at www.longbeach.gov/blueprint.

02/2019